# សូមគោរពជំរាប លោក ហ្វ្រង់ស្វ័រ ហូឡង់ ( FRANCOIS HOLLANDE )

## ប្រធានាធិបតី នៃ សាធារណរដ្ឋ បារាំង

និងជា

## សហប្រធាន នៃសន្និសីទ សន្តិភាព នាទីក្រុងប៉ារីស ស្ដីពីកម្ពុជា ឆ្នាំ១៩៩១

Palais de l'Elysée,

55, Rue du Faubourg  Saint-Honoré , 75008 PARIS

----------

ទីក្រុងប៉ារីស, ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥

***កម្មវត្ថុ*** : ការទាមទារ ឲ្យដោះលែងបាតុករ ១១រូប ដែលត្រូវបានផ្ដន្ទាទោស ដោយរំលោភអំណាចឲ្យជាប់គុក ពី ៧ឆ្នាំ ទៅ ២០ឆ្នាំ ដោយតុលាការមួយ នៅរាជធានីភ្នំពេញ ( កម្ពុជា )។

**លោកប្រធានាធិបតី**

នៅថ្ងៃទី ២១ កក្កដាឆ្នាំ ២០១៥ បន្ទាប់ពីបើកសវនាការមួយ អស់រយៈកាល ប្រហែល២ម៉ោង និងការពិភាក្សា នៃចៅក្រម ប្រហែលដប់ប្រាំនាទី និងដោយអវត្តមាន នៃមេធាវីការពារកូនក្តីផងនោះ  តុលាការ មួយ នៃរាជធានីភ្នំពេញ(កម្ពុជា) បានកាត់ទោស មេដឹកនាំនិងសកម្មជន១១រូប នៃគណបក្សប្រឆាំង គឺគណបក្សសង្គ្រោះជាតិកម្ពុជា (CNRP) ឱ្យជាប់ពន្ធនាគារ រយៈពេល ពី៧ ដល់២០ឆ្នាំ ដោយសារតែ អ្នក ទាំងនេះ បានចូលរួមបាតុកម្មមួយ ដែលតុលាការ បានប្រដូចទៅនិង"ការបះបោរ"មួយ។ ទណ្ឌិតទាំង១១ រូបនោះ គឺមាន លោក មាជ សុវណ្ណារ៉ា, អឿ ណារិទ្ធ, ឃិន រឿន, នាង សុខុន, សាន គឹមហេង, ស៊ុំ ពុទ្ធី, កែ ឃីម, ទេព ណារិន, អាន ប៉ាថាំ, សាន សីហាក់ និង អ៊ុក ពេជ្រ សំណាង។

ហេតុការណ៍ដែលបានកើតមាន គឺកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ នារាជធានីភ្នំពេញ (កម្ពុជា) បាតុកម្មដោយសន្តិវិធីមួយ ដែលបានដឹកនាំ ដោយអ្នកតំណាងរាស្ត្រជាប់ឆ្នោត របស់គណបក្សសង្គ្រោះជាតិ ដោយមានមនុស្សចូលរួម ចំនួនពី ៣០០ ទៅ ៤០០នាក់ មានយុវជនយុវនារី ជាសិស្សនិស្សិតនិងកម្មករ ដើម្បីទាមទារឱ្យបើក"ទីលានសេរីភាព"ជាថ្មី  ដែលជាទីកន្លែងតែមួយគត់ ដែលរដ្ឋអំណាចបានអនុញ្ញាត សម្រាប់ការសំដែងសិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិ របស់ប្រជាពលរដ្ឋ។ នៅចំពោះមុខ បាតុករទាំងនោះ វាមានកងកម្លាំងប៉ូលីស ចំនួន៥០០ប្លាយនាក់ រួមទាំងពួក"កម្លាំងសន្តិសុខ"របស់ទីក្រុង ផង ដែលស្លៀកពាក់ស៊ីវិល និងប្រដាប់ដោយដំបងនិងកាំភ្លើង។ ពួក"សន្តិសុខ" បានផ្ដើមប្រើដំបងវាយប្រហារ បណ្ដេញពួកបាតុករឲ្យចេញពីមុខមាត់ទ្វា នៃទីលាននោះ ។ ការប្រវ៉ាយប្រតប់គ្នា បានចាប់ផ្តើមឡើង ដោយក្រុមបាតុករវ័យក្មេងៗ ដែលបានចាប់ឆក់យកដំបង របស់ពួក"សន្តិសុខ

" វាយបកតបវិញ បណ្ដាលឲ្យមានអ្នករងរបួស(ស្រាល)ទាំងសងខាង ។ ពេលនោះ ក្រុមប៉ូលីសបានចាប់បាញ់គ្រាប់បែក ឧស្ម័ន បង្ហូរទឹកភ្នែក ដើម្បីបំបែកពួកបាតុករ។ ពួកអាជ្ញាធរ បានចោទ នៅពេលបន្ទាប់ថា បាតុកម្មនោះជា«ការបះបោរ "!

ប៉ុន្តែ មកដល់ខែធ្នូ ឆ្នាំ២០១៤ ទើបជនទាំង១១រូប ត្រូវបានចៅក្រម ឲ្យប៉ូលីសចាប់ឃាត់ខ្លួន ជាបន្ត បន្ទាប់ និងធ្វើការចោទប្រកាន់ និងដាក់ពន្ធនាគារ ភ្លាមៗ។ ម្យ៉ាងទៀត ទោះបីជាមានរូបថតនិងវីដេអូ របស់កងប៉ូលីស អំពីព្រឹត្តិការណ៍បាតុកម្មនោះក៏ដោយ ក៏ចៅក្រម ពុំបានរកឃើញ រូបភាពភ័ស្តុតាងអ្វីបញ្ជាក់ថា ទណ្ឌិតទាំង១១រូបនេះ បានប្រព្រឹត្តនូវអំពើហិង្សា ដោយផ្ទាល់នោះទេ។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៥ ពួកគេត្រូវបានដោះលែងទាំងអស់ ឲ្យនៅក្រៅឃុំ ក្រោមកិច្ចធានា។ ពីថ្ងៃទី ២១ខែកក្កដាមុននេះ ការវិនិច្ឆ័យទោស ដ៏ប្រញ៉ាប់ប្រញ៉ាល់ ឱ្យជាប់ពន្ធនាគាររយៈពេលយ៉ាងយូរនោះ គឺជាការបញ្ជាក់យ៉ាងច្បាស់ថា វាជាទង្វើនយោបាយ ដែលបញ្ជាដោយប្រធានគណបក្សកាន់អំណាច គឺលោក ហ៊ុន សែនដែលកំពុងមានការមិនសប្បាយចិត្តជាខ្លាំង ចំពោះក្រុមបាតុករ និងចំពោះការទាមទារតវ៉ា របស់ក្រុមអ្នក តំណាងរាស្ត្រគណបក្សប្រឆាំង កាលពីខែមិថុនា និងខែកក្កដា ឆ្នាំ២០១៥ ពាក់ព័ន្ធនិងបញ្ហាព្រំដែនដីគោក រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។

ការកាត់ទោសនេះសោត បានធ្វើឡើងនៅក្នុងក្របខ័ណ្ឌធំ នៃការបង្ក្រាប សេរីភាព នៃការបញ្ចេញ មតិរបស់ពលរដ្ឋ។ ការបង្ក្រាប បានផ្ដើមពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ ដែលក្រុមទ័ពជើងឆើតមួយរបស់លោកហ៊ុន សែន បានប្រើកាំភ្លើងចំបាំង បាញ់រះ ទៅលើបាតុករ ជាកម្មករឧស្សាហកម្មកាត់ដេរ ដែលបានធ្វើបាតុកម្ម ទាមទារការតម្លើងឡើងប្រាក់ឈ្នួលអប្បបរមា របស់ពួកគេ បណ្ដាលឲ្យមានមនុស្សស្លាប់ចំនួន៥នាក់ និងរបួសជាច្រើនសិបនាក់។ ចាប់តាំងពីពេលនោះមក បាតុកម្មពលរដ្ឋទាំងអស់ ត្រូវបានហាមឃាត់ និងទទួលការបង្ក្រាបដោយហិង្សា ដោយកងកម្លាំងប៉ូលីសនិងកងទ័ព។ នៅបច្ចុប្បន្ន កាលនេះ លោកហ៊ុន សែន ទើបតែបានការអនុម័តពីសភា ដោយមានពហិការរបស់គណបក្សប្រឆាំង នូវច្បាប់បំបាត់សេរីភាពជាច្រើន នៃពួកសមាគមនិងសហជីពសេរី និងពួកអង្គការក្រៅរដ្ឋាភិបាល។ បន្ថែមពីលើនេះទៀត សិទ្ធិមនុស្សផ្សេងៗទៀត ក៏ត្រូវបានគេរំលោភជាប្រព័ន្ធ ដោយការប្រើប្រាស់កម្លាំងហួសហេតុនៃ"ផ្ទាំសន្តិសុខ" និងនិទណ្ឌភាពដែលបុព្វសិទ្ធិរបស់ពួកគេ ។ យ៉ាងដូច្នេះ ក្រុមអ្នកតវ៉ា ដែលភាគ ច្រើន ជាស្ត្រីវ័យក្មេង ប្រឆាំងនឹងការរំលោភ យកដី របស់ពួកគេ ត្រូវបានទទួលការវាយដំ ដោយក្រុមប៉ូលីសឃោជា និងចាប់ដាក់គុក យ៉ាងឃោរឃៅ។

## លោកប្រធានាធិបតី

ស្ថានភាពនៃសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ នៅក្នុងប្រទេសកម្ពុជា មានលក្ខណៈធ្ងន់ធ្ងរណាស់មិនអាចអត់ឱនបានទេ និងបានក្លាយជាគ្រោះថ្នាក់ធំ ដល់ប្រជាជនកម្ពុជាទាំងមូល។
លោកហ៊ុន សែន ដែលជាហត្ថលេខីមួយរូប នៃកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស ឆ្នាំ១៩៩១ ស្ដីពីកម្ពុជា ដែរនោះ បានជាន់ឈ្លី អស់រយៈពេលម្ភៃឆ្នាំមកហើយ លើសិទ្ធិនិងសេរីភាពប្រជាធិបតេយ្យទាំងអស់ ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងក្នុងរដ្ឋធម្មនុញ្ញ នៃប្រទេសកម្ពុជា ដោយ ធន្ទះពង្រីកការគ្រប់គ្រងផ្ដាច់ការ របស់គាត់ លើស្ថាប័ននានាទាំងអស់ របស់ប្រទេស។

ស្ថានភាពយ៉ាងនេះ ត្រូវតែបញ្ចប់។

ដោយសារហេតុការណ៍ទាំងអស់នេះ យើងខ្ញុំ ដែលជាហត្ថលេខី នៃសំបុត្រនេះ សូមអំពាវនាវ នូវបទអន្តរាគមន៍ដ៏ខ្ពង់ខ្ពស់ របស់លោកប្រធានាធិបតី ក្នុងនាមនៃប្រទេសបារាំង ដែលជាសហប្រធាន ជាមួយប្រទេសឥណ្ឌូនេស៊ី នៃសន្និសិទសន្តិភាព ទីក្រុងប៉ារីស ឆ្នាំ១៩៩១ ដើម្បីជំរុញឲ្យរដ្ឋាភិបាល របស់លោកហ៊ុន សែន អនុវត្តិតាមកាតព្វកិច្ចរបស់ខ្លួន គោរពយ៉ាងម៉ត់ចត់បំផុត ចំពោះសិទ្ធិនិងសេរីភាព របស់ ពលរដ្ឋខ្មែរ និងចំពោះគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ដូចដែលមានចែង នៅក្នុងកិច្ចព្រមព្រៀង ទីក្រុងប៉ារីស ឆ្នាំ១៩៩១។ ជាបន្ទាន់នេះ លោកហ៊ុន សែន ត្រូវតែបញ្ឈប់ ការប្រើប្រាស់តុលាការ ដើម្បីបង្ក្រាបក្រុមប្រឆាំងរបប របស់លោក និងធ្វើការដោះលែងសកម្មជនទាំង១១រូបដែលត្រូវ បានចោទប្រកាន់ខាងលើនេះ ជាប្រញ៉ាប់ និងដោយគ្មានដាក់លក្ខខណ្ឌអ្វីទាំងអស់។

ដោយបិតក្នុងមនោសញ្ចេតនាយ៉ាងនេះហើយ ព្រមជាមួយនិងកតញ្ញូតាធម៌ ដ៏ជ្រាលជ្រៅជាទីបំផុតផង យើងខ្ញុំ ក្នុងនាមនៃសហគមន៍ខ្មែរនៃប្រទេសបារាំង

សូមអធិដ្ឋាន ជូនលោកប្រធានាធិបតី សូមមេត្តាទទួល នូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត អំពីយើងខ្ញុំ។

<u>ហត្ថលេខី នៃលិខិត</u> :

1- Mr. SEAN Peng Sè : Président
Comité des Frontières du Cambodge (CFC/CBC)
C/o M. SEAN, 6 Allée des Frênes, 77420 Champs-sur-Marne, France

2- Mr DOUC Rasy : Président
la Ligue Cambodgienne des Droits de l'Homme et du Citoyen (LCDHC).
5, place Gabriel Fauré 94510 La Queue-en-Brie France

3- Mr. SON Quit : Représentant
Fédération des Khmers du Kampuchea Krom pour la Sauvegarde de la Culture et de l'Ethnie (FKKE)
B.P. 69, 93421 – Villepinte Cedex

4- Vénérable CHIN Pao : Chef de la Pagode Cambodgienne à Trembley-en-France
24, allée du Moulin Maheux, 93290 Trembaly-en-France France

5- Mr KRUOCH Rémi: Président
Khmer Professional Network (KPN)
28, rue des perdrix 95800 Courdimanche France

6- Mr. HAM Bunchhay : Vice-Président
Khmers Sangkruos Cheat France ( CNRP-France)
2, cour Pomponne de Bellièvre, 77600 Bussy-Saint-Georges France